# អក្ខរកម្មឌីជីថលក្នុងបរិបទអាស៊ាន និងកម្ពុជា

អក្ខរកម្មឌីជីថលជាគំនិតថ្មីមួយដែលបានលេចឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ៩០ កំឡុងសម័យនៃបដិវត្តន៍អ៊ីនធឺណិត។ បច្ចុប្បន្ននេះ ពិភពលោកកំពុងស្ថិតក្នុងរលកថ្មីនៃបដិវត្តន៍ឧស្សាហកម្មដែលជំរុញដោយការអភិវឌ្ឍ និងការសាយភាយនៃបច្ចេកវិទ្យាឌីជីថល ដែលយើងហៅថាបដិវត្តន៍ឧស្សាហកម្ម ៤.០។ ជាមួយនឹងការមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី ៤ បច្ចេកវិទ្យាថ្មីៗ ដូចជា ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (Internet of Things), បញ្ញាសិប្បនិម្មិត (Artificial Intelligence), និងទិន្នន័យធំ (Big Data) កំពុងត្រូវបានបញ្ចូលទៅក្នុងជីវភាពប្រចាំថ្ងៃ ហើយត្រូវបានប្រើប្រាស់ក្នុងស្ទើរតែគ្រប់វិស័យ។ បច្ចេកវិទ្យាថ្មីៗបានជំរុញឱ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវរបៀបរបបរស់នៅ និងការបំពេញការងាររបស់យើង។ និយោជក និងឧស្សាហកម្មការងារនាពេលបច្ចុប្បន្ននេះទាមទារឱ្យនិយោជិតមានជំនាញអក្ខរកម្មឌីជីថលដើម្បីបង្កើនផលិតភាព និងស័ក្តិសិទ្ធិភាពការងារ។ យោងតាម**អង្គការ UNESCO «"អក្ខរកម្មឌីជីថល" សំដៅដល់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ឌីជីថល ដើម្បីស្វែងរក ប្រើប្រាស់ គ្រប់គ្រង វាយតម្លៃ បង្កើត និងចែករំលែកព័ត៌មាន ដោយសុវត្ថិភាព និងមានភាពត្រឹមត្រូវ ដែលទាមទារទាំងជំនាញបច្ចេកទេស និងការយល់ដឹង សំដៅធ្វើឱ្យសកម្មភាពសេដ្ឋកិច្ច សង្គមកាន់តែប្រសើរ»**។ អក្ខរកម្មឌីជីថលផ្តោតលើចំណុចសំខាន់ចំនួន ៤ គឺ៖

ទី១. ចេះស្វែងរកព័ត៌មានត្រឹមត្រូវលើអ៊ីនធឺណិត
ទី២. ចេះប្រើប្រាស់ និងចែករំលែកព័ត៌មានតាមអនឡាញ
ទី៣. យល់ដឹងពីសុវត្ថិភាពនៃបច្ចេកវិទ្យា
ទី៤. បង្កើតមាតិកាឌីជីថល និងចែករំលែកប្រកបដោយក្រមសីលធម៌។

យោងតាមគេហទំព័រ Datareportal នៅ**ដើមឆ្នាំ ២០២១** នេះ ប្រជាជនកម្ពុជាចំនួន **៨,៨៦ លាននាក់** ជាអ្នកប្រើប្រាស់អ៊ីនធឺណិត និង **១២ លាននាក់** ជាអ្នកប្រើប្រាស់បណ្តាញសង្គម។ ទិន្នន័យទាំងនេះបានបង្ហាញពីសញ្ញាណវិជ្ជមាននៃការចាប់យកបច្ចេកវិទ្យាក្នុងប្រទេសកម្ពុជា។ ម៉្យាងទៀត បច្ចេកវិទ្យាឌីជីថលមួយចំនួន ដូចជា ឧបករណ៍ឆ្លាត, ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការទូទាត់តាមបែបឌីជីថល, ធនាគារអេឡិចត្រូនិក, កុំព្យូទ័រចល័ត និង ព័ត៌មានអនឡាញ ជាដើម កំពុងផ្លាស់ប្តូររបៀបធ្វើការងារតាមបែបប្រពៃណីនៅកម្ពុជា។ ដូច្នេះ ការពង្រឹងជំនាញអក្ខរកម្មឌីជីថលមានសារៈសំខាន់ណាស់ដើម្បីអាចឱ្យប្រទេសកម្ពុជាដើរទាន់និន្នាការថ្មីនៃបដិវត្តន៍ឧស្សាហកម្មទី ៤, សេដ្ឋកិច្ចឌីជីថល និងការផ្លាស់ប្តូរទីផ្សារការងារ។

យ៉ាងណាមិញ សម្រាប់តំបន់អាស៊ានទាំងមូល បច្ចេកវិទ្យាឌីជីថលក៏បានផ្លាស់ប្តូរជីវិតរស់នៅរបស់ប្រជាជនប្រមាណ **៦៦១,៥ លាននាក់**។ រដ្ឋាភិបាលដែលជាសមាជិកអាស៊ានបានយកចិត្តទុកដាក់លើការពង្រឹងអក្ខរកម្មឌីជីថល ដើម្បីអាចទាញយកសក្តានុពលពេញលេញពីការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចឌីជីថលដោយបានអនុម័តដាក់ចេញ **«ផែនការមេឌីជីថលអាស៊ានឆ្នាំ ២០២៥»**។ អាស៊ានមានកម្រិតអភិវឌ្ឍន៍ផ្សេងៗគ្នាដែលនាំឱ្យការអប់រំសាធារណៈមានកម្រិតខុសគ្នា ប៉ុន្តែក្នុងការពង្រឹងអក្ខរកម្មឌីជីថលប្រទេសនីមួយៗដែលជាសមាជិកអាស៊ានបានផ្តោតលើមូលដ្ឋានគ្រឹះ ៤ រួមមាន៖ (១). សមត្ថភាពមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល និងប្រើប្រាស់ធនធានតាមប្រព័ន្ធអនឡាញ (២). ជំនាញក្នុងការវាយតម្លៃភាពត្រឹមត្រូវនៃព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត (៣). ការយកចិត្តទុកដាក់លើព័ត៌មានសម្រាប់ការចែករំលែកបន្ត និង (៤). ការយល់ដឹងពីសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត។

ជំនាញអក្ខរកម្មឌីជីថលសំខាន់ៗមួយចំនួន ដែលមានភាពចាំបាច់សម្រាប់ការបំពេញការងារ និងជីវភាពរស់នៅប្រចាំថ្ងៃ រួមមាន៖ ជំនាញក្នុងការប្រើប្រាស់បណ្តាញសង្គម, ជំនាញក្នុងការធ្វើទីផ្សារតាមបែបឌីជីថល, ជំនាញផ្នែកសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត, ជំនាញក្នុងការគ្រប់គ្រង និងការវិភាគទិន្នន័យ, ជំនាញ Microsoft Office, ជំនាញក្នុងការប្រើប្រាស់ក្លោដ (Cloud), ជំនាញក្នុងការទូទាត់ប្រាក់តាមបែបឌីជីថល (Digital Payment)។

ជំនាញទាំងនេះនឹងផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗដល់ប្រជាពលរដ្ឋ ក្នុងការពង្រឹងទំនាក់ទំនង, សន្សំសំចៃពេលវេលា និងថវិកា, បង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត, ជួយពង្រឹងការសិក្សារបស់សិស្សនិស្សិត, ជួយបង្កើនឱកាសការងារថ្មីសម្រាប់យុវជន, ជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងាររបស់បុគ្គលិក និយោជិត, ជួយបង្កើនការលក់របស់អាជីវកម្ម ព្រមទាំងជួយដល់កំណើនសេដ្ឋកិច្ចជាតិ ជាមួយផលិតភាព និងនវានុវត្តភាពនៅក្នុងវិស័យសេដ្ឋកិច្ច សង្គម ក៏ដូចជាការតភ្ជាប់ខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់តម្លៃនៅក្នុងកម្រិតតំបន់ និងកម្រិតសកលលោក។

## I. អក្ខរកម្មឌីជីថលសម្រាប់បរិវត្តកម្មឌីជីថលក្នុងបរិបទអាស៊ាន

ជាមួយការយកចិត្តទុកដាក់កាន់តែខ្លាំងលើបរិវត្តកម្មឌីជីថល ពិភពលោកកំពុងអភិវឌ្ឍន៍ឆ្ពោះទៅការកសាងសេដ្ឋកិច្ច សង្គមឌីជីថល។ បរិវត្តកម្មឌីជីថលបានជំរុញនវានុវត្តភាព និងផលិតភាពក្នុងគ្រប់សកម្មភាពសេដ្ឋកិច្ច សង្គម រួមទាំងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ និងពង្រឹងសុខុមាលភាពប្រជាពលរដ្ឋ ខណៈដែលព័ត៌មាន, ចំណេះដឹង និងទិន្នន័យត្រូវបានចែករំលែកទូលំទូលាយជាងមុន។ ដើម្បីអាចទាញយកផលប្រយោជន៍ពីបរិវត្តកម្មឌីជីថល ទាមទារឱ្យមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ហើយប្រជាជនមានចំណេះ និងជំនាញសមស្របក្នុងការប្រើប្រាស់បច្ចេកវិទ្យាទាំងនោះ។ បើយោងតាម The Jakarta Post អាស៊ានជាប់ចំណាត់ថ្នាក់ជា**សេដ្ឋកិច្ចធំជាងគេលើពិភពលោកលំដាប់ទី៥ គិតត្រឹមឆ្នាំ២០១៩** ប៉ុន្តែអាស៊ាននៅតែជួបប្រទះបញ្ហា **«គម្លាតឌីជីថល»** រវាងសមាជិកនីមួយៗ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត បើយោងតាម គេហទំព័រ datareportal នៅឆ្នាំ២០២០ ប្រជាជនឡាវ

ប្រមាណ ៦០ ភាគរយ មិនទាន់មានអ៊ីនធឺណិតសម្រាប់ប្រើប្រាស់ ខណៈប្រជាជនសិង្ហបុរី រហូតដល់ប្រមាណ ៨៨,៥% ប្រើប្រាស់អ៊ីនធឺណិត។ មិនតែប៉ុណ្ណោះ បញ្ហា **«គម្លាតជំនាញឌីជីថល»** ក៏បានក្លាយជាបញ្ហាមួយដែលបណ្តាប្រទេសជាសមាជិកនីមួយៗកំពុងយកចិត្តទុកដាក់។ តួយ៉ាង យោងតាមការស្ទង់មតិរបស់ Statista កាលពី**ខែកញ្ញា ឆ្នាំ២០២០** យុវជនដែលរស់នៅទីក្រុងក្នុងតំបន់អាស៊ានប្រមាណ **៤០%** មានកម្រិតអក្ខរកម្មឌីជីថលលើសពីមធ្យម។ រីឯយុវជននៅជនបទប្រមាណត្រឹមតែ **១៦%** ប៉ុណ្ណោះដែលមានជំនាញអក្ខរកម្មឌីជីថលក្នុងកម្រិតល្អ និង**៧%** ក្នុងកម្រិតល្អប្រសើរ។ ដោយឡែក ប្រជាជនវ័យចំណាស់នៅអាស៊ានបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយក្នុងនោះ យោងតាម The ASEAN Post ប្រជាជនវ័យចំណាស់នៅសិង្ហបុរីត្រូវបានគេព្យាករណ៍ថានឹងកើនឡើងដល់ **២៦,៦%** នៃចំនួនប្រជាជនសរុប ត្រឹមឆ្នាំ ២០៣៥។ យោងតាមគេហទំព័រផ្លូវការរបស់អាស៊ាន ប្រជាជនវ័យចំណាស់នៅអាស៊ានកំពុងជួបប្រទះកង្វះអក្ខរកម្មឌីជីថល ដោយសារការប្រើប្រាស់អ៊ីនធឺណិត និងកុំព្យូទ័ររបស់ពួកគាត់មានកម្រិតទាប ដែលនាំឱ្យពួកគាត់មិនទាន់អាចទាញយកផលប្រយោជន៍ពេញលេញពីបច្ចេកវិទ្យា រួមមាន សេវាថែទាំសុខភាពតាមប្រព័ន្ធអនឡាញ និងសេវាសង្គមឌីជីថលជាដើម។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមក្នុងតំបន់ អាស៊ានបានដាក់ចេញនូវវិធានការ និងក្របខណ្ឌគោលនយោបាយមួយចំនួន ដូចជា៖

## សន្និសីទស្តីពីបរិវត្តកម្មឌីជីថលនៃប្រព័ន្ធអប់រំទូទាំងអាស៊ាន

កាលពីខែតុលា ឆ្នាំ២០២០ ប្រទេសវៀតណាមដែលជាប្រធានអាស៊ានក្នុងអាណត្តិឆ្នាំ២០២០ បានរៀបចំ ***"សន្និសីទស្តីពីបរិវត្តកម្មឌីជីថលនៃប្រព័ន្ធអប់រំទូទាំងអាស៊ាន"*** (Conference on the Digital Transformation of Education Systems throughout ASEAN) ដោយមានការចូលរួមពីរដ្ឋមន្ត្រីក្រសួងអប់រំនៃប្រទេសជាសមាជិកអាស៊ាន, តំណាងយុវជន, គ្រឹះស្ថានអប់រំ, ស្ថាប័នឯកជន និងអង្គការនានា ដោយបានអនុម័ត**សេចក្តីថ្លែងការណ៍រួម**ដែលបង្ហាញពីការប្តេជ្ញាចិត្តក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍជំនាញអក្ខរកម្មឌីជីថលដល់យុវជនក្នុងតំបន់។ សន្និសីទនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ចូលការពង្រឹងអក្ខរកម្មឌីជីថលទៅក្នុង**ផែនការការងារអាស៊ានស្តីពីការអប់រំ ឆ្នាំ២០២១-២០២៥** (ASEAN Work Plan on Education 2021 -2025)។ ថ្នាក់ដឹកនាំអាស៊ានបានទទួលស្គាល់សារៈសំខាន់នៃជំនាញបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍សម្រាប់ជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ច សង្គមអាស៊ាន ដោយបានផ្តោតលើការអប់រំពេញមួយជីវិត និងលើកទឹកចិត្តដល់ការពង្រឹងអក្ខរកម្មឌីជីថល ព្រមទាំងសមត្ថភាពសម្របខ្លួនដល់កុមារ និងយុវជន។ ថ្នាក់ដឹកនាំអាស៊ានក៏បានទទួលស្គាល់ពីសារៈសំខាន់នៃជំនាញអក្ខរកម្មឌីជីថលដែលទាក់ទងនឹងសុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិតដល់កុមារ ហើយពួកគេនឹងបន្តសហការជាមួយស្ថាប័នឯកជនដើម្បីផ្តល់នូវជំនាញសមស្របដល់កុមារ និងយុវជនតាមរយៈការអប់រំនៅតាមគ្រឹះស្ថានអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីកាត់បន្ថយគម្លាតជំនាញឌីជីថលនៅក្នុងតំបន់។




## ផែនការមេឌីជីថលអាស៊ាន ឆ្នាំ២០២១ - ២០២៥

អាស៊ានបានអនុម័តដាក់ចេញ **«ផែនការមេឌីជីថលអាស៊ាន ឆ្នាំ២០២១-២០២៥»** កាលពីខែមករា ឆ្នាំ២០២១ ក្នុងគោលបំណងសម្រេចបាននូវ (១). ពន្លឿនការស្តារឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ (២). បង្កើនគុណភាព និងការគ្របដណ្តប់នៃហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត (៣). ការផ្តល់សេវាឌីជីថលដែលអាចទុកចិត្តបាន និងការពារអ្នកប្រើប្រាស់ពីគ្រោះថ្នាក់នានា (៤). ទីផ្សារប្រកួតប្រជែងប្រកបដោយនិរន្តរភាពសម្រាប់ការផ្គត់ផ្គង់សេវាកម្មឌីជីថល (៥). បង្កើនគុណភាព និងការប្រើប្រាស់សេវារដ្ឋាភិបាលអេឡិចត្រូនិក (៦). សេវាកម្មឌីជីថលដើម្បីភ្ជាប់អាជីវកម្ម និងសម្រួលពាណិជ្ជកម្មឆ្លងប្រទេស (៧). បង្កើនសមត្ថភាពរបស់អាជីវកម្ម និងប្រជាជនក្នុងការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល (៨). បរិយាបន្នឌីជីថលក្នុងតំបន់អាស៊ាន។ បច្ចុប្បន្ននេះ បញ្ហាប្រឈមចម្បងមួយដែលរាំងស្ទះអាស៊ានក្នុងការសម្រេចបាននូវគោលបំណងខាងលើគឺ**កង្វះអក្ខរកម្មឌីជីថល**។ ដើម្បីពន្លឿនការស្តារឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ អាស៊ានបានផ្តោតលើការផ្តល់នូវជំនាញឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុឌីជីថល និងសេវាកម្មឌីជីថលដែលកំពុងរីកចម្រើនផ្សេងទៀត ដើម្បីអាចឱ្យប្រជាជនអាស៊ានទាញយកផលប្រយោជន៍ពីសេវាកម្មឌីជីថលទាំងនោះកំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩នេះ។ មិនតែប៉ុណ្ណោះ ដើម្បីបង្កើនគុណភាព និងការគ្របដណ្តប់នៃហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត អាស៊ានមិនត្រឹមតែផ្តោតលើការផ្តល់សេវាអ៊ីនធឺណិតគ្រប់គ្រាន់ដល់ប្រជាជនប៉ុណ្ណោះទេ តែក៏ផ្តោតលើការផ្តល់ឧបករណ៍ និងធនធានគ្រប់គ្រាន់ដល់សាលារៀន សហគមន៍ និងអង្គការសប្បុរសធម៌ ដើម្បីអាចឱ្យពួកគេបង្រៀនជំនាញឌីជីថលជាមូលដ្ឋានដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋបាន។ ម៉្យាងទៀត ដើម្បីបង្កើនសមត្ថភាពរបស់អាជីវកម្ម និងប្រជាជនក្នុងការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល អាស៊ានបានផ្តោតលើការជំរុញការអភិវឌ្ឍជំនាញឌីជីថល

កម្រិតខ្ពស់ ដែលជំនាញទាំងនេះកំពុងមានតម្រូវការខ្លាំង។ អាស៊ាននឹងបង្កើតកម្មវិធីសិក្សាសម្រាប់វគ្គបណ្តុះបណ្តាលលើការសរសេរកូដដែលទទួលស្គាល់ដោយគ្រប់ប្រទេសក្នុងតំបន់អាស៊ាន។




## II. អក្ខរកម្មឌីជីថលសម្រាប់បរិវត្តកម្មឌីជីថលក្នុងបរិបទកម្ពុជា

ការមកដល់នៃបដិវត្តន៍ឧស្សាហកម្ម ៤.0 និង វិបត្តិជំងឺកូវីដ-១៩ បានជំរុញឱ្យមានកំណើននៃការប្រើប្រាស់អ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា។ យោងតាមគេហទំព័រ Datareportal ចំនួនអ្នកប្រើអ៊ីនធឺណិតនៅកម្ពុជាបានកើនឡើងដល់ចំនួនប្រមាណ **៨,៨៦លាននាក់** នៅដើមឆ្នាំ២០២១។ ប៉ុន្តែ បើយោងតាមការស្ទង់មតិរួមគ្នារបស់ Mekong Big Data, DataU, វិទ្យាស្ថានជាតិ NIPTICT និងសហគ្រិនខ្មែរ បានបង្ហាញថា**កង្វះថវិកា និងកង្វះជំនាញ**ជាបញ្ហាប្រឈមចម្បងសម្រាប់អាជីវកម្មក្នុងស្រុកដើម្បីត្រៀមខ្លួនសម្រាប់បរិវត្តកម្មឌីជីថល។ ដូច្នេះ ប្រទេសកម្ពុជាត្រូវវិនិយោគបន្ថែមទៀតក្នុងការពង្រឹងជំនាញអក្ខរកម្មឌីជីថលដល់ប្រជាជនដើម្បីអាចឆ្លើយតបនឹងបរិវត្តកម្មឌីជីថល។ ខាងក្រោមនេះជាសកម្មភាពសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ក្នុងការពង្រឹងអក្ខរកម្មឌីជីថលនៅកម្ពុជា រួមមាន៖

- យោងតាម "**ផែនទីចង្អុលផ្លូវ ស្តីពី ផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩**" ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ **ក្រសួងទេសចរណ៍ និងសហភាពសហព័ន្ធយុវជនកម្ពុជា សហការជាមួយមជ្ឈមណ្ឌលកម្ពុជា ៤.0** បាននិងកំពុងបន្តរៀបចំ «**វគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា**» រួមមានអក្ខរកម្មមូលដ្ឋាន និងអក្ខរកម្មជំនាញ ដោយផ្តោតលើប្រធានបទដែលមានសារៈសំខាន់សម្រាប់ការបំពេញ

ការងារ និងការប្រកបអាជីវកម្មនៅក្នុងវិស័យទេសចរណ៍។ កម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលនេះ នឹងចូលរួមអភិវឌ្ឍន៍ចំណេះ និងជំនាញឌីជីថលសម្រាប់បុគ្គលិកឯកជន ម្ចាស់អាជីវកម្មក្នុងវិស័យទេសចរណ៍ ក៏ដូចជាមន្ត្រីទេសចរណ៍ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីស្តារកំណើនទេសចរណ៍ ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ចូលរួមដល់ការត្រៀមលក្ខណៈសម្បត្តិដើម្បីជំរុញអនុវត្ត "**ផែនការយុទ្ធសាស្ត្រស្តីពីការបើកទទួលទេសចរណ៍វ៉ាក់សាំង**" និង"**វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ២០២១-២០២៣**" ដែលរាជរដ្ឋាភិបាលទើបបានអនុម័តកាលពីពេលថ្មីៗនេះ។ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ យើងបានរៀបចំ "**ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា**" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍នៃរដ្ឋសភា, ជាប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលកម្ពុជា ៤.០ និង**ឯកឧត្តមបណ្ឌិត ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលនិងឯកជន ដើម្បីស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩។



យោងតាម **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១ - ២០៣៥»** ប្រជាជនកម្ពុជាប្រមាណ ៣០% ប៉ុណ្ណោះ មានជំនាញឌីជីថលកម្រិតមូលដ្ឋាន ហើយនិស្សិតកម្ពុជាប្រមាណ ២៨% ប៉ុណ្ណោះ ដែលប្រើប្រាស់កុំព្យូទ័រសម្រាប់ការសិក្សាក្នុងកម្រិតថ្នាក់ឧត្តមសិក្សា។ ការពង្រឹងអក្ខរកម្មឌីជីថលមានភាពចាំបាច់ណាស់សម្រាប់ប្រទេសកម្ពុជាក្នុងការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការជាក់លាក់មួយចំនួនដូចជា៖

- រៀបចំក្របខណ្ឌរួមស្ដីពីការលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រីនៅតាមក្រសួង ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្ដុះបណ្ដាលជំនាញ និងការកសាងភាពជាអ្នកដឹកនាំឌីជីថល
- រៀបចំផែនការរយៈពេលខ្លី និងមធ្យមសម្រាប់ការជំរុញការចាប់យក និងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និងការចាត់ចែងការងារ ព្រមទាំងការជំរុញ និងការលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និងមន្ត្រី នៅតាមមូលដ្ឋាន និងសាធារណជន
- រៀបចំផែនការរយៈពេលខ្លី និងមធ្យមសម្រាប់ការជំរុញការចាប់យក និងការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង  និងការចាត់ចែងការងារ ព្រមទាំងការលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថល និងភាពជាអ្នកដឹកនាំឌីជីថល នៅក្នុងវិស័យឯកជន, និង
- បង្កើនការផ្ទេរធនធាន និងកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកា ក៏ដូចជាកិច្ចសហប្រតិបត្តិការនានា ពីសំណាក់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន សម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ។



យោងតាម **«ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣»** ដើម្បីត្រៀមខ្លួនសម្រាប់ទីផ្សារការងារក្នុងសតវត្សរ៍ទី២១នេះ **ក្រសួងអប់រំ យុវជន និងកីឡា**បានដាក់ចេញនូវផែនការសកម្មភាពសំខាន់ៗសម្រាប់ការពង្រឹងអក្ខរកម្មឌីជីថលក្នុងវិស័យអប់រំកម្ពុជា ដូចជា៖

- នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ស្ដីពី ការលើកកម្ពស់ការអប់រំតាមបែបឌីជីថល ក្រសួងមានគោលបំណងបញ្ជ្រាបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ឱ្យក្លាយជាឧបករណ៍សម្រាប់ការបង្រៀន និងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំទាំងមូល សំដៅឱ្យសិស្ស និស្សិតមាននូវចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សរ៍ទី២១ ព្រមទាំងធានាឱ្យសិស្ស និស្សិតកម្ពុជាគ្រប់រូបដែលបញ្ចប់ការសិក្សា មានចំណេះដឹង និងបំណិន បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីមានលទ្ធភាពក្នុងការបន្តការសិក្សា និងបំពេញការងារវិជ្ជាជីវៈ។

- ក្រសួងអប់រំ យុវជន និងកីឡា បានផ្ដោតលើការពង្រឹងជំនាញឌីជីថល និងលើកកម្ពស់ចំណេះដឹងអនុវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាសម្រាប់យុវជន ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មដំណាក់កាលទី៤ ដោយបង្កើត**ក្លឹបស្ទែម**នៅក្នុងក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជា, អនុវត្តកម្មវិធីប្រើប្រាស់ព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការសិក្សា និងបណ្ដុះបណ្ដាលពីចម្ងាយ និងអភិវឌ្ឍន៍កម្មវិធីបណ្ដុះបណ្ដាលអក្ខរកម្មឌីជីថល។



- **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** សហការជាមួយ**ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ** (AUSAID) និង**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា** (UNDP) បានរៀបចំនូវកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល សម្រាប់សហគ្រាសធុនតូច និងមធ្យម។ កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ ក្នុងនោះបានផ្តោតសំខាន់លើការលើកកម្ពស់ការយល់ដឹងពីអត្ថប្រយោជន៍ និងពង្រឹងសមត្ថភាពរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។




## III. សន្និដ្ឋាន

ជារួម អក្ខរកម្មឌីជីថលពិតជាមានសារៈសំខាន់ និងភាពចាំបាច់ សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា ក៏ដូចជានៅក្នុងក្របខណ្ឌតំបន់អាស៊ាន នាពេលបច្ចុប្បន្ន និងអនាគត ស្របពេលជាមួយនឹងការមកដល់នៃបដិវត្តន៍ឧស្សាហកម្ម ៤.០ និងការប្រែប្រួលឥតឈប់ឈរនៃបរិបទសង្គម។ កម្ពុជា និងអាស៊ាន មានភាពចាំបាច់ក្នុងការចាប់យកកាលានុវត្តភាពដ៏ពិសេសនេះ តាមរយៈការសម្របខ្លួន និងចាប់ឱកាសពីសក្តានុពលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០។ ការឈានទៅសម្រេចបានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឌីជីថលមួយពេញលេញ ស្របតាមចក្ខុវិស័យវែងឆ្ងាយរបស់កម្ពុជា និងតំបន់ ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមដំណើរលើផ្លូវមួយនេះប្រកបដោយភាពម្ចាស់ការ ព្រោះថាការសិក្សាជាច្រើនបានបង្ហាញថា នៅក្នុងបរិបទបដិវត្តន៍ឧស្សាហកម្ម បញ្ហាប្រឈមសំខាន់ដែលប្រទេសកំពុងអភិវឌ្ឍន៍ត្រូវដោះស្រាយដើម្បីទាញយកប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗ គឺការបង្កើនការយល់ដឹង និងការដាក់ចេញយុទ្ធសាស្ត្រ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ជាមួយការយកចិត្តទុកដាក់បន្ថែម និងបង្កើនការវិនិយោគនៅក្នុងយុទ្ធនាការអក្ខរកម្មឌីជីថល។ នៅក្នុងយុគសម័យឌីជីថលនេះ “**អក្ខរកម្មឌីជីថល**” នឹងចូលរួមយ៉ាងសំខាន់ដល់ការលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ សំដៅធានាបាននូវសង្គម-សេដ្ឋកិច្ចមួយ ប្រកបដោយសមធម៌ បរិយាបន្ន និងគង់វង្ស៕

# ឯកសារយោង


- *The Roles of Digital Literacy, Technology Literacy, and Human Literacy to Encourage Work Readiness of Accounting Education Students in the Fourth Industrial Revolution Era, ចូលអានថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, https://knepublishing.com/index.php/KnE-Social/article/view/4031/8300*
- *Digital 2021: Cambodia, ចូលអានថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, https://datareportal.com/reports/digital-2021-cambodia*
- *New digital push for MSMEs, ចូលអានថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.phnompenhpost.com/business/new-digital-push-msmes*
- *Skills Needed for Cambodia to Thrive in the Industry 4.0's Labor Market, ចូលអានថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១, https://cambodianess.com/article/skills-needed-for-cambodia-to-thrive-in-the-industry-40s-labor-market*
- *ASEAN must embrace digitization for development, ចូលអានថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.eastasiaforum.org/2019/05/03/asean-must-embrace-digitisation-for-development/*
- *10 Digital Skills That Can Make Students Instantly Employable in 2022, ចូលអានថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១, https://digitalmarketinginstitute.com/blog/10-digital-skills-that-can-make-students-instantly-employable*
- *The Top 10 Digital Skills Tech Companies are Looking for Today, ចូលអានថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១, https://digitalskillsglobal.com/blog/the-top-10-digital-skills-tech-companies-are-looking-for-today*
- *Importance of Digital Literacy: 13 Ways It Can Improve Lives, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១, https://techboomers.com/importance-of-digital-literacy*
- *9 Reasons Why Digital Literacy Skills Are Important, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១, https://builddigitalspace.com/9-reasons-why-digital-literacy-skills-are-important/*
- *Digital Literacy, ចូលអានថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១, https://speedmatters.org/speedmatters-2/digital-literacy*
- *Digital 2020: Laos, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១, https://datareportal.com/reports/digital-2020-laos*
- *Self-perceived digital literacy among young people in ASEAN countries in 2020, by residence, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.statista.com/statistics/1247960/asean-perceived-digital-literacy-of-youth-by-residence/*

- Southeast Asia's rapidly ageing population, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១, https://theaseanpost.com/article/southeast-asias-rapidly-ageing-population
- Consolidated Strategy on the Fourth Industrial Revolution for ASEAN, ចូលអានថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១, https://asean.org/consolidated-strategy-on-the-fourth-industrial-revolution-for-asean/
- Digital ASEAN, ចូលអានថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.weforum.org/projects/digital-asean
- Digital Literacy in Education Systems Across ASEAN, ចូលអានថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.unicef.org/eap/media/7766/file/Digital%20Literacy%20in%20Education%20Systems%20Across%20ASEAN%20Cover.pdf
- ASEAN commits the role of ICT in Education, ចូលអានថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.newdelhitimes.com/asean-commits-the-role-of-ict-in-education/
- Digital masterplan to boost ASEAN economy over the next five years, ចូលអានថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.dksh.com/global-en/insights/digital-masterplan-to-boost-asean-economy-over-the-next-five-years
- ASEAN Digital Masterplan 2025, ចូលអានថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១, http://agreement.asean.org/media/download/20140119121135.pdf
- Higher budgets and more skills 'needed to embrace digital transformation', ចូលអានថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.khmertimeskh.com/50765233/higher-budgets-and-more-skills-needed-to-embrace-digital-transformation/
- កម្មវិធីបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា, រៀបចំដោយក្រសួងទេសចរណ៍ សហភាពសហព័ន្ធយុវជនកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជា ៤.០, ខែសីហា ឆ្នាំ២០២១
- កម្រងសៀវភៅមេរៀនវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលក្នុងវិស័យទេសចរណ៍កម្ពុជា, រៀបចំដោយក្រសួងទេសចរណ៍ សហភាពសហព័ន្ធយុវជនកម្ពុជា និងមជ្ឈមណ្ឌលកម្ពុជា ៤.០, ខែតុលា ឆ្នាំ២០២១
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១, https://www.moeys.gov.kh/index.php/en/policies-and-strategies/3206.html#.YaBcYdBBw2w
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ២០២១-២០៣៥, ចូលអានថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១, https://mef.gov.kh/download-counter?post=7116

www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center

Cambodia 4.0